D99/3/21

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 10 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

កាលបរិច្ឆេទ: ១៣ តុលា ២០០៨

សាធារណៈ:

សេចក្តីសម្រេចចំពោះការកំណត់លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលប្តឹងចំពោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ តែប៉ុណ្ណោះ

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**
ការ សាវុត្ថ
François ROUX

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

00231603



១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" កត់សម្គាល់ឃើញមាន "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលប្តឹងចំពោះដីកាបញ្ជូន កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨" ដែលបណ្តឹងឧទ្ធរណ៍នេះបានដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

២. វិធាន ៧៧(៣)នៃវិធានផ្ទៃក្នុង នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ ចែងថា:

(ក) ប្រធានអង្គបុរេជំនុំជម្រះ ត្រូវផ្ទៀងផ្ទាត់ថាសំណុំរឿងនោះ មានភាពពេញលេញនិងកំណត់កាលបរិច្ឆេទសវនាការ ។

(ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា "បណ្តឹងឧទ្ធរណ៍នេះ មិនចាំបាច់មានសវនាការផ្ទាល់មាត់ទេ។ [...] ភាគីនានាអាចដាក់សេចក្តីសង្ខេបឱ្យបានគ្រប់គ្រាន់ស្តីពីបញ្ហាអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធផ្សេងៗ ជូនទៅអង្គបុរេជំនុំជម្រះ តាមរយៈសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន[...]។ សហព្រះរាជអាជ្ញា ក៏ទទួលស្គាល់ផងដែរ អំពីសេចក្តីត្រូវការនូវដំណោះស្រាយមួយឱ្យបានឆាប់រហ័ស អំពីបញ្ហាតាមផ្លូវច្បាប់នានាដែលនៅសល់ ដើម្បីអាចចាប់ផ្តើមបើកសវនាការជាសាធារណៈឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន"។[១]

៤. នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ នៅក្នុងសេចក្តីសន្និដ្ឋានតបចំពោះបណ្តឹងឧទ្ធរណ៍ ("សេចក្តីសន្និដ្ឋានតបរបស់សហមេធាវីការពារក្តី") សហមេធាវីការពារក្តីស្នើទៅអង្គបុរេជំនុំជម្រះឱ្យបដិសេធបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាថាគ្មានមូលដ្ឋានច្បាប់ ដោយមិនចាំបាច់បើកសវនាការឡើយ។[២]

៥. បន្ទាប់ពីពិចារណាការយល់ឃើញរបស់ភាគី ដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាន អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ អាចយកមកធ្វើការសម្រេច ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ តែប៉ុណ្ណោះ។

---

[១] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងចំពោះដីកាបញ្ជូន កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨, ដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ D99/3/3 វាក្យខណ្ឌទី ៩។

[២] សារណាតបរបស់សហមេធាវីការពារក្តី ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨, ដាក់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ D99/3/8 វាក្យខណ្ឌទី ១៧។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានទទួលការជូនដំណឹងជាមុន ពីសហព្រះរាជអាជ្ញាថា មិនមានបំណងដាក់សេចក្តីសន្និដ្ឋានតបចំពោះសារណាតបរបស់សហមេធាវីការពារក្តីឡើយ អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[៣]។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

បណ្តឹងឧទ្ធរណ៍នេះ អាចយកមកធ្វើការសម្រេច ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ តែប៉ុណ្ណោះ។ ៗ

ភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨
**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន**

---

[៣] សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ស្តីពីសារណាតបរបស់សហមេធាវីការពារក្តី ទៅនឹងបណ្តឹងឧទ្ធរណ៍ចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨ D99/3/9 វាក្យខណ្ឌទី ៣។